# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ៥៧០៣...អបស/ប្រកស

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៧

## ប្រកាស

## ស្តីពី

## ការកំណត់ឯកសណ្ឋាន និង ផ្លាកសញ្ញាសំគាល់ថ្មីរបស់ការិយាល័យចត្តាឡីស័ក

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/០៣ ចុះថ្ងៃទី ២៤.០១.៩៦ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញប្រកាសលេខ ១៩៣ អបស ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ក្រសួងសុខាភិបាលស្តីពីការកំណត់តួនាទី ភារកិច្ចរបស់ក្រុមចត្តាឡីស័កនៅតាមច្រកទ្វារព្រំដែន
- បានឃើញលិខិតលេខ ២៨០/០៦ អបស.ប្រជផ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រសួងសុខាភិបាល ស្តីពីសេចក្តីណែនាំនៃការអនុវត្តន៏ភារកិច្ចចត្តាឡីស័ក នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ដូចដែលមានចែងក្នុងនិយ័តកម្មសុខភាពអន្តរជាតិ ឆ្នាំ ២០០៥ ឧបសម្ព័ន្ធ ១ ផ្នែក "ខ"
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## <u>សំរេច</u>

**ប្រការ ១** - ធ្វើការកែលំអ ឯកសណ្ឋាន និង ផ្លាកសញ្ញាសំគាល់ថ្មី សម្រាប់មន្ត្រីចត្តាឡីស័កប្រើប្រាស់ក្នុងពេលប្រតិបត្តិការ ។

**ប្រការ ២** - ឯកសណ្ឋាន និង ផ្លាកសញ្ញាសំគាល់ថ្មីរបស់មន្ត្រីចត្តាឡីស័ក ត្រូវបានកំណត់ដូចតទៅ :

ក- <u>ឯកសណ្ឋានកំណត់ជូនមន្ត្រីចត្តាឡីស័កម្នាក់១ក្នុងមួយឆ្នាំ</u>

- ខោជើងវែងពណ៌ទឹកប៊ិច ចំនួនពីរ ផលិតពីក្រណាត់ឡែន ចង្កេះតថ្ពេរបង្កប់ជីបភ្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀងដេរបង្កប់តាមថ្នេរ ។

- អាវវែងដៃវែង ឬ ខ្លី ចំនួនពីរ ផលិតពីក្រណាត់កាមែល កខុប ថ្មេរខុប ប៉ូលស្មា ហោប៉ៅពីរ ដេរប៉ះបត់ផ្នត់កណ្តាលមានគំរបរាងស្លឹកពោធិ កាត់ស្រុងវែងជើងត្រង់ ដាក់ក្នុងខោ ។
- ស្បែកជើងផលិតពីស្បែក ពណ៌ខ្មៅ កខ្លី មានចងខ្សែ និង ស្រោមជើងពណ៌ខ្មៅ ចំនួនពីរសំរាប់ក្នុងមួយឆ្នាំ ។
- ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ចំនួនពីរសម្រាប់
- ក្រវ៉ាត់កពណ៌ទឹកប៊ិច ចំនួនពីរ
- មួកកាស្កែត ចំនួនមួយ ៖ មួកកាស្កែតផលិតពីក្រណាត់ពណ៌ទឹកប៊ិច ដែលផ្នែកខាងមុខ លើកណ្តាប់វិណ្ឌមានភ្ជាប់រូបព្រះសង្ហាពណ៌មាស ទំហំ-កំពស់ ៧.៨ ស.ម ទទឹង ៦.៨ ស.ម ។ ប៉ែកខាងក្រោមនៃជើងមួក និងខាងក្រោមព្រះសង្ហា មានកណ្តាប់វិណ្ឌធ្វើពីក្រណាត់ខ្សែនពណ៌ស្លឹកឈើព័ទ្ធជុំវិញខាងក្រោមកណ្តាប់វិណ្ឌប៉ែកខាងមុខមានក្បាំងពណ៌ខ្មៅ ។ ខាងមុខក្រោមកណ្តាប់វិណ្ឌមាន កម្រងខ្សែសយពណ៌មាសដែលនៅខាងចុងខ្សែភ្ជាប់ដោយឡេវព្រះសង្ហាពណ៌មាស ។ ខាងលើចុងក្បាំងមួកខាងមុខមានដាក់ខ្សែទឹកមាសរាងមូល ។
- មួកកាតិបចំនួនមួយ ៖ មួកកាតិប ផលិតពីក្រណាត់ទឹកប៊ិច ក្បាំងខាងមុខលើកណ្តាប់វិណ្ឌ មានប៉ាក់ព្រះសង្ហាពណ៌លឿង ខាងលើក្បាំងមុខមានប៉ាក់ក្បាច់ស្លឹកឈើ ចែកជាពីរស្របតាមចុងក្បាំងមួក និងមានប៉ាក់សញ្ញាចត្តាឡីស័កចំកណ្តាលពណ៌លឿង ។

ខ- ផ្លាកសញ្ញាសំគាល់ ៖

ខ-១ ផ្លាកសញ្ញាក្រសួងសុខាភិបាល ៖ ផលិតអំពីសាច់ក្រណាត់ ប៉ាក់ដោយកុំព្យូទ័រ និងអំបោះសូត្រមានរាងមូល ដែលមានបន្ទាត់ផ្ចិតទំហំ ៦ ស.ម បិតភ្ជាប់លើដើមដៃអាវខាងឆ្វេង ។

ខ-២ ផ្លាកសញ្ញាចត្តាឡីស័ក ៖

ផ្លាកសញ្ញាចត្តាឡីស័កធ្វើពីស្ពាន់ បិតភ្ជាប់នឹងស្បែក ព្យួរនៅហោប៉ៅអាវខាងស្តាំ ៖ ផ្លាកសញ្ញានេះមានរាងមូល ទំហំ ៥ ស.ម ។ អក្សរពណ៌ទឹកប៊ិច សរសេរថា “MINISTRY OF HEALTH” នៅផ្នែកខាងលើ និង “QUARANTINE SERVICE” នៅផ្នែកខាងក្រោម ដែលខ័ណ្ឌដោយក្បាច់ផ្កាច័ន្ទពណ៌ទឹកប៊ិចចំនួនពីរ ។ ខាងក្នុងមានរូបយុថ្កា, ចង្កូតរថយន្ត, ស្លាបយន្តហោះ ពណ៌លឿងទុំ រូបពស់ពណ៌បៃតងខ្ចី លានអណ្តាតពណ៌ក្រហម . ក្បាច់ស្លឹកឈើពណ៌បៃតងខ្ចីចែកជាពីរផ្នែក ព័ទ្ធព័ន្ធរូបខាងក្នុង ។ នៅផ្នែកខាងចុងនៃយុថ្កាមានសរសេរអក្សរ ថា "ចត្តាឡីស័ក" ពណ៌ទឹកប៊ិច ហើយនៅខាងលើយុថ្កាមានសរសេរអក្សរថា “CDC” ។

ខ-៣ ផ្លាកសញ្ញាសំរាប់ពាក់លើចុងកអាវ ឆ្វេង-ស្តាំ ៖

កំណត់យកផ្លាកសញ្ញាសំគាល់ចត្តាឡីស័ក ដែលមានទំហំ ១.៥ ស.ម ធ្វើអំពីស្ពាន់ពណ៌លឿង ។

ខ-៤ <u>ផ្លាកសំគាល់ឈ្មោះមន្ត្រីដាក់លើហោប៉ៅអាវខាងស្ដាំ</u> :

កំណត់យកផ្លាករាងបួនជ្រុងទ្រវែង ទំហំបណ្ដោយប្រវែង ៩ ស.ម ទទឹង ២.២ ស.ម ធ្វើអំពីជាតិជ័រឹងថ្លា ។ ផ្ទៃខាងក្នុងពណ៌ខៀវ ព័ទ្ធជុំវិញដោយខ្សែបន្ទាត់ពណ៌ទឹកមាសបិតជិត ។

ផ្លាកនេះចែកជាពីរផ្នែកគឺ :

- ខាងស្ដាំទំហំ ២.៥ ស.ម គឺជាផ្លាកសញ្ញារបស់ចត្តាឡីស័ក
- ឈ្មោះមន្ត្រីសរសេរជាអក្សរខ្មែរ និង អក្សរឡាតាំង ពណ៌ទឹកមាស ។

**ប្រការ ៣** - ក្នុងពេលប្រតិបត្តិការមន្ត្រីចត្តាឡីស័កទាំងពីរភេទ ត្រូវស្លៀកពាក់ឯកសណ្ឋាន និង ផ្លាកសញ្ញាសំគាល់ អោយបានត្រឹមត្រូវដូចដែលបានកំណត់ក្នុងប្រការ ២ ។

**ប្រការ ៤** - ជនក្លែងបន្លំ ដោយស្លៀកពាក់ឯកសណ្ឋាន និង ផ្លាកសញ្ញាសំគាល់ ដូចមានចែងក្នុងប្រការ ៣ ត្រូវផ្ដន្ទាទោស តាមច្បាប់ជាធរមាន ។

**ប្រការ ៥** - រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦** - ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល និង ការិយាល័យចត្តាឡីស័ក ត្រូវអនុវត្តតាមប្រកាសនេះ ។

**ប្រការ ៧** - ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ្ជ. នុត_សុខុម

<u>**ចម្លងជូន**</u> :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម
- ក្រសួងទេសចរណ៍

<u>"ដើម្បីជូនជ្រាបជាព័ត៌មាន"</u>

- ឯកសារកាលប្បវត្ត